ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ៣៩,៥១ ហិកតា នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២៧៥/១៧ អបខ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
- បានឃើញលិខិតលេខ ៣៨៦៨ កសក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៣៩,៥១ ហិកតា ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជា ដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ជាំជុះជាក់ស្ដែងទំហំ ៣៨,០៤ ហិកតា និងផ្ទៃដីទំហំ ១,៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិរវៀងពើង **ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) និង(២) នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ០៦ គ្រួសារ នៅភូមិរវៀងពើង **ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៣** : ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជន ចំនួន ០៦ ក្បាលដី ជូនប្រជាពលរដ្ឋ ០៦ គ្រួសារ ស្ថិតនៅ ភូមិរវៀងពើង **ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ** ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃទី...ខែ...ឆ្នាំ២០១៧ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ៣៩,៥១ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៦គ្រួសារ នូវផ្ទៃដីទំហំ ៣៨,០៤ហិកតា ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំជុះជាក់ស្តែង និងដីទំហំ ១,៤៧ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ស្ថិតនៅភូមិអើងពើង ឃុំស្ពុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ




កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៥... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

សំ ណាង

លេខ...២៤២...ជទសស.កស្ព
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៥... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ស្ពឺ

នាង ម៉ាឡៃ

លេខ...២៧៥/១៧...អបខ
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៥... ឆ្នាំ២០១៧
អភិបាលនៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

វ៉ី សំណាង

ឧបសម្ព័ន្ធ....... ចំណុចនិយាមការព្រំដី ដែលស្នើសុំកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ០៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង
ស្ថិតនៅភូមិអែងពើង ឃុំស្ដុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

## តារាងចំណុចនិយាមកា

Projection UTM, Zone 48N, Datum WGS 84

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 444616 | 1260181 | 34 | 444670 | 1259598 | 67 | 444986 | 1260334 |
| 2 | 444605 | 1260151 | 35 | 444692 | 1259634 | 68 | 445000 | 1260371 |
| 3 | 444607 | 1260087 | 36 | 444709 | 1259671 | 69 | 445029 | 1260382 |
| 4 | 444608 | 1260080 | 37 | 444711 | 1259674 | 70 | 445024 | 1260400 |
| 5 | 444630 | 1260053 | 38 | 444712 | 1259728 | 71 | 445004 | 1260399 |
| 6 | 444634 | 1260012 | 39 | 444788 | 1259730 | 72 | 445000 | 1260439 |
| 7 | 444646 | 1260006 | 40 | 444818 | 1259808 | 73 | 444986 | 1260441 |
| 8 | 444682 | 1259997 | 41 | 444882 | 1259825 | 74 | 444939 | 1260455 |
| 9 | 444688 | 1259970 | 42 | 444983 | 1259846 | 75 | 444942 | 1260538 |
| 10 | 444697 | 1259890 | 43 | 445096 | 1259891 | 76 | 444965 | 1260540 |
| 11 | 444662 | 1259889 | 44 | 445050 | 1259936 | 77 | 444985 | 1260546 |
| 12 | 444624 | 1259888 | 45 | 445035 | 1259992 | 78 | 444983 | 1260562 |
| 13 | 444612 | 1259889 | 46 | 445035 | 1260010 | 79 | 445020 | 1260571 |
| 14 | 444581 | 1259886 | 47 | 445037 | 1260046 | 80 | 445022 | 1260585 |
| 15 | 444577 | 1259865 | 48 | 445041 | 1260050 | 81 | 445098 | 1260599 |
| 16 | 444572 | 1259824 | 49 | 445044 | 1260059 | 82 | 445091 | 1260622 |
| 17 | 444586 | 1259823 | 50 | 445045 | 1260074 | 83 | 445086 | 1260651 |
| 18 | 444582 | 1259802 | 51 | 445044 | 1260081 | 84 | 445085 | 1260676 |
| 19 | 444578 | 1259788 | 52 | 445005 | 1260080 | 85 | 445082 | 1260708 |
| 20 | 444573 | 1259759 | 53 | 444996 | 1260073 | 86 | 445075 | 1260741 |
| 21 | 444565 | 1259703 | 54 | 444966 | 1260065 | 87 | 445077 | 1260756 |
| 22 | 444563 | 1259684 | 55 | 444971 | 1260139 | 88 | 445069 | 1260782 |
| 23 | 444564 | 1259673 | 56 | 444960 | 1260141 | 89 | 444660 | 1260681 |
| 24 | 444560 | 1259638 | 57 | 444961 | 1260173 | 90 | 444642 | 1260502 |
| 25 | 444555 | 1259599 | 58 | 445091 | 1260237 | 91 | 444639 | 1260473 |
| 26 | 444551 | 1259556 | 59 | 445076 | 1260240 | 92 | 444637 | 1260459 |
| 27 | 444548 | 1259517 | 60 | 445060 | 1260245 | 93 | 444630 | 1260424 |
| 28 | 444560 | 1259515 | 61 | 445041 | 1260251 | 94 | 444629 | 1260379 |
| 29 | 444570 | 1259513 | 62 | 445021 | 1260254 | 95 | 444632 | 1260367 |
| 30 | 444593 | 1259513 | 63 | 445021 | 1260276 | 96 | 444636 | 1260362 |
| 31 | 444610 | 1259511 | 64 | 445023 | 1260300 | 97 | 444639 | 1260348 |
| 32 | 444657 | 1259509 | 65 | 444986 | 1260300 | 98 | 444636 | 1260304 |
| 33 | 444656 | 1259558 | 66 | 444986 | 1260317 | 99 | 444629 | 1260285 |

កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៥... ឆ្នាំ២០១៧
ប្រធានក្រុមវាស់វែង

**សំ_ណាង**

លេខ...២៤២.....ជនសស.កស្ក
បានឃើញ និងពិនិត្យត្រឹមត្រូវ
កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៥... ឆ្នាំ២០១៧
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់
និងសុរិយោដី ខេត្តកំពង់ស្ពឺ

**តាប់ ម៉ាឡៃ**

លេខ.....២៧៥/១៧.អបខ
បានឃើញ និងឯកភាព
កំពង់ស្ពឺ,ថ្ងៃទី...២៩... ខែ...៦... ឆ្នាំ២០១៧
អភិបាល នៃគណៈអភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ស្ពឺ

**វ៉ី សំណាង**